ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៤ ភាគទី ៣

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៥

គ.ស. ១៩៤២

# បញ្ជីរឿង

ទំព័រ

១ — មហាភារតៈ (សង្ខេប) . . . . . . . . . . . . . . . . . . . . ៣

២ — ប្រវត្តិពួកឧបាសក-ឧបាសិកា ជាសាវករបស់ព្រះពុទ្ធជាម្ចាស់: ទី៣ ប្រវត្តិចិត្ត-គហបតី . . . . . . . . . . . . . . . . . . . . ៧

៣ — ច្បាប់វិធុរបណ្ឌិត (តមកនឹងចប់) . . . . . . . . . . . . . . . . ១០

៤ — ភូមិសាស្ត្រសង្ខេបនៃប្រទេសផ្សេងៗ: អំពីប្រទេសអល្លឺម៉ាញ . . . . . . ១៣

៥ — ពង្សាវតារភូមា, ស្រង់យកអំពីគោលបារកផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . ១៧

៦ — សេចក្ដីប្លែកៗ . . . . . . . . . . . . . . . . . . . . ២១

៧ — រឿងព្រេងខ្មែរ: "រឿងសេដ្ឋីបីនាក់" . . . . . . . . . . . . . . . . ២៦

## រូបក្រៅរឿង

រូបភាពសីហ៍អង្គុយ សក់គេឆ្លាក់ជាក្បាច់ រចនាបែបប្រាសាទបាខែង ព.ស. ១៤៤៣ . . . ១

# TABLE DES MATIÈRES


| | Pages |
|---|---|
| 1. Mahābhārata (sommaire) | 3 |
| 2. Vie des disciples laïcs du Buddha. — III. La vie de Citta-Gahapati | 7 |
| 3. Chbab-Vidhurapaṇḍit (suite et fin) | 10 |
| 4. Géographie sommaire de divers pays: L'Allemagne | 13 |
| 5. Histoire de Rome. Extrait de divers documents de l'histoire universelle (suite) | 17 |
| 6. Notes variées | 21 |
| 7. Conte populaire cambodgien inédit: "Légende de trois richards" | 26 |

HORS-TEXTE

| | |
|---|---|
| Phnom-Bakheng — Lion assis. Crinière à stylisation décorative (début du X^e siècle) | 1 |

# សេចក្ដីជូនដំណឹង

## អំពីព្រះរាជបណ្ណាល័យ កម្ពុជា

គម្ពីរមង្គលត្ថទីបនីបាលី ព្រះរាជបណ្ណាល័យបានចាត់ចែងបោះពុម្ពចប់សព្វគ្រប់ហើយ ចែកចេញជា ៤ ភាគ គឺ ភាគទី ១ ដំឡៃ ១ ក្បាល ២៛.០០ ភាគទី ២ ដំឡៃ ១ ក្បាល ២៛.៥០ ភាគទី ៣ ដំឡៃ ១ ក្បាល ៣៛.០០ ភាគទី ៤ ដំឡៃ ១ ក្បាល ២៛.៧០ ។ អស់លោក-អ្នកសិក្សាគម្ពីរបាលីដល់ថ្នាក់មង្គលត្ថទីបនីហើយ សឹងមានសេចក្ដីត្រូវការគម្ពីរនេះទាំងអស់គ្នា ដូច្នេះ សូមចូលទៅជាវនៅព្រះរាជបណ្ណាល័យទីកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យតាមត្រូវការចុះ ។

អស់លោក-អ្នកចុះឈ្មោះជាវព្រះត្រៃបិដកគង់មានសេចក្ដីទន្ទឹងចង់បើកព្រះត្រៃបិដកឲ្យបានឆាប់ៗរាល់គ្នា ចំពោះភាគថ្មីៗតៗទៅ ដូច្នេះ ព្រះរាជបណ្ណាល័យសូមជូនដំណឹងថា ព្រះត្រៃបិដកភាគទី ៣២ (សុត្តន្តបិដក) បានបោះពុម្ពសម្រេចហើយ សូមអញ្ជើញទៅបើកយកចុះ ។ ឯភាគទី ៣៣ - ៣៤ នឹងតៗទៅនោះរោងពុម្ពកំពុងដេរកាត់ចងក្រងនឹងបោះពុម្ពជាលំដាប់ៗតៗទៅឥតឈប់ខានទេ ។

✲

✲ ✲

ព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយរឿងថ្មី ១ រឿងទៀតហើយ គឺមគ្គុទ្ទេសក៍នគរ ជាសៀវភៅនាំផ្លូវទៅមើលបុរាណស្ថាននគរវត្ត នគរធំនៅខែត្រសៀមរាប ។ មគ្គុទ្ទេសក៍នេះមាន ២ ភាគ ភាគទី ១ និយាយពី

ពង្សាវតារសម័យបុរាណនៃក្រុងកម្ពុជា និងរបាព្រះមហាក្សត្រសម័យនគរ មានសេចក្ដីរៀបរៀងតាមគោលចារឹកផ្សេងៗដែលអ្នកប្រាជ្ញបានស្រាវជ្រាវរកឃើញ ភាគទី ១ នេះ ១ ក្បាលថ្លៃ ០៛.៦០ ។

ភាគទី ២ មានសេចក្ដីពន្យល់ពីផ្លូវដែលត្រូវទៅមើលប្រាសាទអស់នោះ និងបង្ហាញឲ្យដឹងច្បាស់ថា ប្រាសាទណាកសាងឡើងក្នុងសម័យណា ? ព្រះមហាក្សត្រអង្គណា ទ្រង់កសាង? កសាងឡើងដើម្បីជាប្រយោជន៍អ្វី? ហើយបានបង្ហាញឲ្យយើងស្គាល់បែបផែនប្រាសាទ ឬក្បាច់រចនាដែលកើតឡើងដោយស្នាដៃខាងពួកសាសនាព្រាហ្មណ៍ ឬខាងពួកពុទ្ធសាសនាមហាយាន និងហីនយានដោយឡែកថែមទៀតផង ។

នៅខាងក្នុងសៀវភៅមគ្គុទ្ទេសក៍ភាគទី ២ នេះ មានរូបប្រាសាទ និងរូបផ្សេងៗ ជាចំនួនច្រើន ហើយមានផែនទីសម្រាប់នាំផ្លូវទៅមើលបុរាណស្ថានផ្សេងៗ ជាអក្សរខ្មែរយ៉ាងច្បាស់លាស់ផង ទុកជាលោក-អ្នកមិនដែលអញ្ជើញទៅនគរវត្តសោះ គ្រាន់តែមានផែនទីដែលខ្ចាស់ជាប់មកនិងមគ្គុទ្ទេសក៍ភាគទី ២ នេះ ក៏លោក-អ្នកអាចអញ្ជើញទៅមើលនគរវត្ត នគរធំ ដោយខ្លួនឯងបាន មិនបាច់វង្វេងផ្លូវឬភាន់ច្រឡំឡើយ ។ សៀវ-ភៅមគ្គុទ្ទេសក៍ភាគទី២ នេះថ្លៃ ១ ក្បាល ១៛.២០ ។

សៀវភៅអស់នេះ មានចំណាយនៅព្រះរាជបណ្ណាល័យ និងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។



រូបភពសីហ៍អង្គុយ សក់គេធ្លាក់ជាក្បាច់រចនាបែបប្រាសាទបាខែង ព. ស. ១៤៤៣

# មហាភារតៈ

មានជនជាតិខ្មែរជាចំនួនច្រើន ដែលមិនទាន់ស្គាល់ឈ្មោះកំណាព្យធំ ១ នេះរបស់ប្រទេសឥណ្ឌា តែជនជាតិខ្មែរបុរាណគេស្គាល់ច្បាស់ណាស់ ហើយរឿងនេះស្ទើរតែមានចម្លាក់នៅគ្រប់អង្គ និងប្រាសាទបុរាណ ក្នុងមហាអាណាចក្រខ្មែរសម័យបុរាណ ដែលគេបានស្រង់យករឿងរ៉ាវមកអំពីកាព្យនេះ ហើយឆ្លាក់ជារឿងរ៉ាវទុកនឹងជញ្ជាំងប្រាសាទ និងខាងលើខ្លោងទ្វារនៅតាមប្រាសាទផ្សេង ៗ ។ ហេតុនេះហើយបានជាយើងគិតឃើញថា ការនាំយករឿងនេះមកចុះផ្សាយក្នុងទស្សនាវដ្ដីជាការគាប់ប្រសើរមួយ ទុកជាទីរឭកនៃមហាកាព្យនេះ ដែលមានរឿងរ៉ាវជាទីចាប់ចិត្តនៃវិស្វករខ្មែរអំពីបុរាណ ហើយនាំឲ្យកំណាព្យធំនេះមានជីវិតរស់ឡើងវិញផង ។

ឯកំណាព្យធំនេះមានសេចក្ដីរៀបរៀងជាគាថា ចំនួន ៤០០.០០០ គាថា ក្នុងគាថានីមួយ ៗ មាន ៤ បាទ ក្នុង ១ បាទ ៗ មានអក្សរ ៨ និង ១១ ហៅថាស្លោក និងត្រិស្តុក[១] អស់នេះជួនកាលមានសេចក្ដីរៀបរៀងជារបៀបសីលធម៌, ជារបៀបប្រសាសនោបាយ, ជារបៀបសាសនា, ជារបៀបព្រះអភិធម្ម ។

---

១ ពាក្យថាស្លោក បានដល់គាថានីមួយៗមាន ៤ បាទ ៨ អក្សរ ក្នុងបាទនីមួយៗក្នុង ១ គាថាមាន ៣២ អក្សរ ។ ឯត្រិស្ដុភៈបានដល់គាថាមាន ៤ បាទដែរ តែក្នុង ១ បាទៗមាន ១១ អក្សរ មួយគាថា ៤៤ អក្សរ ។

កាព្យមហាភារតៈនេះជាពង្សាវតារយ៉ាងធំ ហើយចាស់ជាងរឿងរាមាយណៈផង ។ កាព្យនេះលើកដំកើងក្រិស្ណៈជាជាតួព្រះវិស្ណុបែងភាគ-ចុះមកក្នុងលោក ។ គេមិនអាចនឹងកំណត់អំពីកំណើតរបស់កាព្យនេះយ៉ាងប្រាកដបានទេ តែកាព្យនេះដែលគេបានរៀបរៀង ហើយកែចំរើនឡើងនោះរាប់ជាវេលាច្រើនឆ្នាំដែរ នៅក្នុងរវាងពុទ្ធសករាជ ១០០ និង ៩០០ ឆ្នាំ ។ គេឃើញមានសេចក្ដីសារស័ព្ទនេះ នៅក្នុងរឿងរ៉ាវជាន់ដើមខាងពុទ្ធសាសនាដែរ ។ ឯប្រទេសឥណ្ឌាក្នុងសម័យដែលតែងកាព្យនេះឡើង គង់បានស្គាល់នានាប្រទេសខ្លះហើយ ការតែងកាព្យនេះទើបនាំឲ្យទឹកដល់រឿងរ៉ាវក្នុងប្រទេសឯទៀតៗ គឺក្រិក, ប៉ែរ្ស៍, ចិន និងចំណែក ៗ របស់ឥណ្ឌៀដោយឡែក ។ ឯពួកវណ្ណៈដែលជារបៀបឥណ្ឌូ គង់មានបរិបូណ៌ហើយ (ក្នុងសម័យនោះ) ទើបគេឃើញមានសេចក្ដីនិយាយប៉ះពាល់ដល់បុរាណស្ថានពុទ្ធសាសនានិងហិណ្ឌូ ។ ឯព្រះគ្រប់អង្គរបស់ឥណ្ឌៀក៏មាននិយាយក្នុងរឿងនេះទាំងអស់ ។

រឿងមហាភារតៈនេះមានសារម្មកថា ១ និយាយអំពីរឿងរ៉ាវរបស់ពួកទេវតានិងពួកមនុស្ស ដែលជារឿងសំខាន់ក្នុងពង្សាវតារ ដូចមានសេច-ក្ដីសង្ខេបដូចតៈ:

មានបងប្អូន ២ នាក់ ឈ្មោះធ្រិតរាស្ត្រ ១ និងបាណ្ឌុ ១ ដែលអាពុកឈ្មោះភិស្មៈបានចិញ្ចឹមបីបាច់ថែរក្សា ។ តមក ធ្រិតរាស្ត្រមានប្រពន្ធ

ឈ្មោះគន្ធារី មានបុត្រ ១០០ នាក់ ហៅថាកុរុ ៗ ឯបាណ្ឌុមានប្រពន្ធ ២ នាក់ ប្រពន្ធមួយឈ្មោះម៉ាទ្រី កាលបូជាសពប្តីលើគំនរឧសនោះ នាងក៏ធ្វើពិធីសាតី (គឺលោតសម្លាប់ខ្លួនឯងក្នុងគំនរភ្លើងនោះ) ទៅ ៗ ប្រពន្ធមួយទៀតឈ្មោះនាងប្រីថា ចិញ្ចឹមកូនទាំង៥ ឬដែលហៅថាបាណ្ឌុ ដែលតាមពិតនោះ ពួកបាណ្ឌុជាកូនទេព្តា ហៅថា យុធិស្ថិរ: (កូនព្រះធម៌) អជ៌ុន: (កូនព្រះឥន្ទ្រ) នកុល:និងសហទេវ (កូនព្រះអស្វិន) ៗ

ឯក្រុងហស្តិនាបុរ: ពួកកុរុប្រជុំគ្នាហើយសម្រេចថាទៅអញ្ជើញពួកបាណ្ឌុឲ្យមកលេងល្បែងស្កាភ្នាល់គ្នា ដោយល្បិចឆបោកដោយយកស្រុកទេសជាដើមភ្នាល់ ហើយត្រូវបន្ថយអស់ទាំងព្រះរាជអំណាច ៗ ដំបូងព្រះបាទយុធិស្ថិរ:ទ្រង់លេងល្បែង:នោះទៅ ក៏ទ្រង់ចាញ់អស់ទាំងព្រះរាជទ្រព្យរបស់ខ្លួនស្រុកទេសនិងប្អូន ៗ របស់ទ្រង់ហើយនិងខ្លួនទ្រង់ ៗ នៅទីបំផុតទ្រង់លេងហើយខូចមហេសីដែលមានបងប្អូន ៥ នាក់ ឈ្មោះនាងក្រិស្នា ជារាជធីតារបស់ក្សត្រទ្រុបទ ៗ ទ្រង់នៅលេងតទៅទៀតដរាបដល់គេនិរទេសទ្រង់ ហើយនៅទីបំផុតត្រូវបំបរបង់បងប្អូនទាំង៥និងមហេសីរបស់ទ្រង់ឲ្យទៅនៅក្នុងព្រៃជាវេលា ១២ ឆ្នាំ ៗ ក្នុងសៀវភៅ ១ ហៅថា "វន" និយាយរៀបរាប់អំពីជីវិតដែលនៅក្នុងព្រៃ ហើយមានរឿងកំរ៉យ៉ាងឆ្ងាយ និងរឿងកំរ៉ដែលជួយឲ្យពួកដែលត្រូវគេនិរទេសអត់ធន់ទ្រាំទ្រសេចក្តីព្រួយលំបាកក្នុងជីវិតដែលនៅក្នុងព្រៃបាន ៗ

លុះដល់១២ឆ្នាំក្រោយកន្លងមក ទើបបងប្អូនទាំង៥នាក់នឹងមហេសី ចេញទៅស្វែងរកទីពំនាក់នឹងស្ដេចវិរាដៈ ហើយប្រមូលជាពួកសម្ពន្ធមិត្តជួយស្ដេចនោះក្នុងការច្បាំងតទល់នឹងពួកកុរុ ។ ឯព្រះបាទក្រិស្ណៈ ជាតួវិស្ណុបែងភាគចុះមក ក៏បានចេញទៅច្បាំងនៅខាងពួកបាណ្ឌុ អជ៌ុនបានប្អូនស្រីធ្វើជាប្រពន្ធ ។

នៅខាងដើមនៃសេចក្ដីពន្យល់ ដែលនិយាយអំពីចម្បាំងក្នុងពាក្យកាព្យដែលហៅថា ភគវ័ទ្គីតៈនោះ មានសេចក្ដីពីរោះណាស់ រឿងនេះគេបានប្រែចេញជាច្រើនគ្រប់ៗភាសាក្នុងទ្វីបអឺរុប កាព្យនេះហើយដែលយើងទឹកសង្ឃឹមថា យើងនឹងប្រែចេញជាខ្មែរក្នុងថ្ងៃទីមួយមិនខាន ។

ចម្បាំងនេះចប់ចុះដោយកិស្ណៈបរាជ័យ ទើបគេផ្ដាស់ឲ្យទ្រោណៈឡើងក្រួតក្រាស្រុកកុរុ ។ មានសៀវភៅ១ និយាយពន្យល់អំពីពួកដែលមានជីវិតរស់នៅ ខាងពួកកុរុបានចេញច្បាំងក្នុងវេលាយប់ បានសម្លាប់អស់ទាំងពួកទាហាន លើកលែងតែពួកបាណ្ឌុចេញ ឯកិស្ណៈត្រឡប់មានជីវិតរស់ឡើងវិញយ៉ាងអស្ចារ្យ ហើយទេសនាតាមផ្លូវសាសនា និយាយអំពីសីលធម៌នឹងដំណើររបស់ជីវិត ។ ឯរឿងក៏ទាំងពួងដែលនិយាយអំពីចម្បាំង សឹងមានចម្លាក់ជាក្បាច់នៅថ្នាក់ក្រោមនៃប្រាសាទនគរវត្ត ។

(នៅមានត)

# ប្រវត្តិពួកឧបាសកឧបាសិកា

## ជាសាវកសាវិការបស់ព្រះពុទ្ធជាម្ចាស់

៣ – **ចិត្តគហបតី** កើតក្នុងត្រកូលសេដ្ឋី ក្នុងស្រុកមច្ឆិកា-សណ្ឌៈ ដែនមគធៈ ។ មានរឿងដំណាលថា កាលពេលលោកប្រសូតនោះមានភ្លៀងជាផ្កាឈូក ៥ យ៉ាង ធ្លាក់ចុះមកគរពេញស្រុកត្រឹមជង្គង់ ទើបមាតាបិតាតាំងនាមកូនថា ចិត្តកុមារ ព្រោះស្ថានទីទូទៅវិចិត្រត្រកាលដោយផ្កាឈូក ។ លុះធាត់ធំចំរើនឡើង ក៏បានទទួលមុខក្រសួងសេដ្ឋីជាជំនួសបិតា ។ ក្នុងសម័យនោះ ព្រះមហានាមត្ថេរដែលនៅក្នុងពួកបញ្ចវគ្គិយបានទៅកាន់ស្រុកមច្ឆិកាសណ្ឌៈ ចិត្តគហបតីបានជួប ក៏មានចិត្តជ្រះថ្លា ទើបបវារណាលោកសុំឲ្យនៅ ហើយរៀបចំទីកន្លែងឲ្យលោកស្នាក់នៅអម្ពាតកាកម ។ ព្រះថេរៈឃើញឧបនិស្ស័យធម៌របស់ចិត្តគហបតី ទើបសំដែងធម៌ចែកអាយតនៈទាំង ៦ ប្រការ ចិត្តគហបតីបានស្តាប់ព្រះធម្មទេសនារបស់លោក ក៏បានសម្រេចអនាគាមិផល ។ តមកថ្ងៃ ១ ព្រះឥសិទត្តត្ថេរទៅនៅក្នុងទីនោះ បានចោទឆ្លើយដោះប្រស្នាគ្នាទៅវិញទៅមករួចហើយចៀសចេញទៅ ។ ក្នុងថ្ងៃមួយនោះ សេដ្ឋីបាននិមន្តសុំឲ្យព្រះមហកត្ថេរសំដែងឥទ្ធិបាដិហារ្យ លោកក៏បានសំដែងបាដិហារ្យប្រកបដោយតេជោសមាបត្តិរួចហើយចៀសចេញទៅ ។ តមកសម័យក្រោយ

ទៀត ព្រះអគ្គសាវកមានភិក្ខុ ១ ពាន់រូបជាបរិវារ បានត្រាច់ចារិកទៅកាន់ទី
នោះ ឯចិត្តគហបតីបានចាត់ការទទួលយ៉ាងអឹកធឹក ព្រះសុធម្មត្ថេរជាចៅ
អាវាសនៅទីនោះកើតចិត្តច្រណែនឫស្យា ដោយការហេតុថាចិត្តគហបតី
វែងមុខលោក ព្រោះទៅនិមន្តព្រះអគ្គសាវកមុន ទើបមកនិមន្តលោក
ជាក្រោយ ធ្វើឲ្យលោកអន់ចិត្តមិនព្រមទទួលនិមន្តរបស់ចិត្តគហបតីទទូច
អង្វរយ៉ាងណាក៏លោកនៅតែមិនព្រមទទួលនិមន្ត ព្រឹកឡើងជាថ្ងៃថ្វាយ
ទានដល់ព្រះអគ្គសាវកព្រមទាំងភិក្ខុសង្ឃ ព្រះសុធម្មត្ថេរចេញទៅបិណ្ឌ-
បាត ហើយបានចៀងទៅអែបមើលលាភសក្ការៈដែលគហបតីចាត់ថ្វាយ
ដល់ព្រះអគ្គសាវក ៗ ចិត្តគហបតីបានឃើញក៏និមន្តឲ្យលោកគង់ លោក
មិនព្រមគង់ ហើយថែមទាំងពោលពាក្យដៀមដាមដល់ជាតិកំណើត
របស់គហបតីផង ហើយលោកត្រឡប់មកគាល់ព្រះបរមសាស្តា ក្រាប
បង្គំទូលឲ្យទ្រង់ជ្រាប ៗ ព្រះអង្គទ្រង់លើកទោសហើយឲ្យទៅសុំខមា
ទោសនឹងចិត្តគហបតី ព្រះសុធម្មត្ថេរក៏ធ្វើតាមព្រះពុទ្ធដីកា បានសុំខមា
ទោសនឹងចិត្តគហបតីហើយ បំពេញព្យាយាមចំរើនសមណធម៌នៅអម្ពាត
ការាមនោះឯង ក៏បានសម្រេចព្រះអរហត្តជាព្រះខីណាស្រព ៗ

ប៉ែកខាងចិត្តគហបតីបានចូលទៅគាល់ព្រះបរមសាស្តា បានស្តាប់
ព្រះធម្មទេសនាដែលទ្រង់សំដែងអំពីអាយតនៈ៦ ប្រការ កើតចិត្តជ្រះថ្លា

យ៉ាងក្រៀវក្រា បានបំពេញទានបរិច្ចាគ មានមហាជននាំគ្នាមកជួយជាច្រើន ។ តមកសម័យមួយ ព្រះបរមសាស្តាទ្រង់សំដែងចិត្តសំយុត្តឲ្យជាហេតុ ទើបទ្រង់តាំងក្នុងដំណែងឯតទគ្គៈក្នុងពួកឧបាសកដែលជាធម្មកថិក ។

ចប់ប្រវត្តិរបស់ចិត្តគហបតីតែប៉ុណ្ណោះ ។

# ច្បាប់វិធុរបណ្ឌិត

( តមកនឹងចប់ )

ដូចទៀនគន្ធយាផ្ក នោះនូវប្រែពត់ពុំត្រង់ យកប្រេងទូនរំគងន់ ពេល ក្តៅពត់ពុំត្រង់បាន ។ ដូចពុតពាលសក់ឡូក ចិត្តអាក្រក់ធ្វើលើកលាន យល់ធម៌ផ្សន្ទាន ចិត្តពុំចូលពុំចង់ស្ដាប់ ។ ទឹកហូរចេញចូលណា ដោយច្បាប់ថាលោកប្រើត្រាប់ ជាញាតិសន្តានស្រាប់ ត្រូវប៉ត្រាប់អំពើ ពាល៍ ។ អ្នកតូចឥតមេត្រី ចង់ជាក្ដីមែនឆ្ងាយចង់ ទ្រព្យធននាយពុំគង់ បទបំណាច់ឯងឲ្យបាត់ ។ ទោះបីយល់គេខុស កុំប្រទូស្តប្រទះមាត់ យល់ ថ្លុកប្រើប្រយ័ត្ន ត្រូវលែងសាឆសេចក្ដីធម៌ ។ ទោះបីជាតិអ្នកបេះ មានបំណោះឥតដឹងអាថ៌ ប្រើធូនប្រើដោះសា ដោយសណ្ដាប់ព្រះធម៌ ស្រាយ ។ រំពាក្យពាលកម្ញៅ ពុំដឹងជ្រៅដោយបរិយាយ នាំពាក្យទៅ និយាយ ដើរប្រាប់ប្រាយឲ្យអប្រិយ ។ អម្ចាស់អ្នកប្រើទៅ រំលរំលាំនៅពុំ ខ្ចបក្ដី ស្វែងទ្រព្យសរពើភ្ញី អង់អាលស៊ីទ្រព្យសាធារណ៍ ។ ប្រើទៅ ជាកជទូត ចិត្តពុំស្លូតធ្វើក្រៅសារ បេះបាំនូវអស់អាថ៌ ជាកជសារទូកតមៗ ជាកជបុរោហិត កជបណ្ឌិតគ្រូហោរធំ ពុំមានប្រព្រឹត្តក្រម លោក ក្រៃលែងអ្នកសាមាន្យ ។ ទោះគេស្រឡាញ់ហោង ប្រើបេះស្នេហ៍ស្រ-ឡាញ់ថ្កាន បណ្ដាលហឫទ័យក្សាន្ត សមស្នេហាមិត្រមេត្រី ។ ទោះ បេះក្ដីកិច្ចកល ប្រើបេះយល់អាថ៌នោះមិញ អប្រិយប្រើបៀសចេញ

ទូរទ័ឆ្ងាយឲ្យបាត់ដាន ។ ពុំគួរយកខ្លួនគប់ គួរតែស្អប់ហេតុសាមាន្យ កុំ
សេពអាស្រូវប្រាណ ពាក្យដំនៀលត្រូវឯក្អែក ។ កុំយកពងមាន់ជ្រើ ៣ដ៏
លើសំបុកក្អែក អ្នកដំកុំជ្រើដែក អ្នកប្រមឹកកុំជ្រើស្រា ។ កុំបីយកសំរិទ្ធិ
ជ្រើអ្នកស្និតនោះពុំជា រីឯអ្នកចំការ កុំយកត្រាប់ត្រសក់ជ្រើ ។ ទោះស្រូវ
កោជសាលី ទុកក្នុងម្ពក់នោះឃាត់ប្រើ កុំមានចិត្តសើរើ យកមកជ្រើនៅ
ផលស័យ ។ បញ្ចើបួនប្រការ ពិចារណាឲ្យអស់ក្តី កុំមានពាក្យអប្រិយ
ខ្លាចចំណេរដំនៀលថា ។ កាលក្អែកចេញស៊ីលុះ កត្រីនោះមៀមកោក្តា
មានសឹករកអាសា ទៀបអាត្មាកុំឃ្លាតឆ្ងាយ ។ ទឹកឡើងស្រមោចលង់
លុះចំណង់ត្រីសប្បាយ ស្រមោចក៏អន្តរាយ លុះចំណេរចំណាប់ល្អ ។
លុះទឹករីងស្អួតទៅ ត្រីផងនៅអាត្មាមរណ៍ អនេកអន្តរ លុះចំណេរ
ស្រមោចស្អួង ។ នេះមានពៀររវេរ ពីបុរាណហោង សព្វឋានពុំ
កន្លង ហេតុចំណងពីព្រេងព្រឹទ្ធ ។ បានធុកបទពាទី បានជាក្តីបទចិត្តឯង
ហេតុចិត្តវៀចវង្វេង ចង់ទ្រព្យឯងបទចិត្តស្រោល ។ រីអ្នកខ្ជួញខ្ជិល
ខ្សោយ កុំបីឲ្យកាន់ទូវការ ពាលាអន្ធពាល កុំឲ្យធមិឥតចិត្តចង់ ។
ទោះបានសត្វបក្សី ប្រក្រតីគិតស្លាប់ចង់ រក្តីដឹងសព្វអង្គ ប្រើគិតផ្សង
គំនិតច្បាប់ ។ ប្រើត្រាប់ឯតាំងយូ ក្រឯគ្រូពុំគួរត្រាប់ កុំយល់មួយ
កណ្តាប់ ជាមួយទឹងកំបង់ដៃ ។ កុំយល់សសោភា កុំបីថាជាខ្មៅក្រៃ
បន្តិចនេះប្រពៃ គួរត្រាប់កុំបីភ្លេចឡើយ ។ ទោះបីដំរីបាត់ លោកប្រើ

:

ស្កាត់ក៏ជាត្រើយ តាមទឹកដំរីហើយ កុំបីដើរទឹកជើងលា ។ ទោះទូកដាច់សាត់សោះ យកទូកស្មោះទៅតាមគ្នា នេះពាក្យព្រេងលោកថា ទុកជាច្បាប់តម្រាប់កេ្តិ៍ ។ វែអ្នកមានប្រាជ្ញា សង្វាតយល់ពុំថេរ ទុក្ខសោកភ័យចំណោរ ប្រើផ្តាច់ផ្តិលនិពសស្ថាន ។ ស្រុកមានសឹកកុំបី ទៅជួញខ្មី រកធនធាន រីខ្លួនកំព្រាព្រាណ ក្ររកក្រទូវមាសប្រាក់ ។ ចោរឃ្មឹយតាំវៃប្លន់ ឥតតំបន់ណាទឹកលាក់ ខ្លួនឯងឥតបើជាក់ សរពើទ្រព្យបាត់អស់ឯង ។ តំបន់នទីជ្រៅ កុំងូតនៅម្នាក់ឯងលេង ទឹកហូររំពងក្រែង កុំបីអាលចុះទូកចូង ។ ក្រពើក្រពេញពាំ សាហាវចាំសព្វព្រែកផង ចាំចាប់ដោយបំណង បីដូចខ្យល់ទឹកភ្លើងព្រៃ ។ ដំរីគជសារធំ ទុតារជុំជាញដល់នៃ ប្រើរត់ចៀសចេញវៃ កុំយកខ្លួនទៅទប់ទល់ ។ កំឡាំងតិចពិតអស្ត ឯងជាអ្នកឯណាយល់ ទើបបានខ្លួនទុំពិល លុះនៅដួលអាត្មាមរណ៍ ។ ព្រះធម៌នេះជាច្បាប់ ប្រសើរគាប់ឲ្យអស់នរ អ្នកផងចាំបានបរិបូណ៌ដល់ត្រិពិធសួគ៌ហោង ។

ច្បាប់វិធុរបណ្ឌិតចប់តែប៉ុណ្ណោះ

ភូមិសាស្ត្រសង្ខេប

នៃនានាប្រទេស

# អំពីភូមិសាស្ត្រសង្ខេប នៃប្រទេសអល្លឺម៉ាញ

**ទីតាំងនិងអាណាខេត្ត** — ប្រទេសអល្លឺម៉ាញតាំងនៅចន្លោះប្រទេសបារាំងនិងប្រទេសប៉ូឡូញ ។

**ទំហំដី** — ៤៧២.០៣៤ គីឡូម៉ែត្រក្រឡា ក្រោយមហាយុទ្ធសង្គ្រាម គឺសម្រេចតាំងអំពីឆ្នាំ ១៩១៩ មក តែក្នុងឆ្នាំ ១៩៤១ នេះ មហាយុទ្ធសង្គ្រាមនៅទ្វីបអឺរ៉ុបមិនទាន់ស្រេច កាលបើស្រេចហើយមុខជាមានការប្រែប្រួលយ៉ាងសំបើមមិនខាន ។

**ផ្ទៃផែនដី** — ប្រទេសអល្លឺម៉ាញមានផ្ទៃផែនដីមិនស្មើគ្នា តំបន់ខ្លះជាទីរាបខ្ពស់ តំបន់ខ្លះជាទីរាបទំនាប តំបន់ខ្លះជាទីមានភ្នំប្រកបដោយព្រៃឈើធំៗ មានផ្ទៃផែនដីចេញជា ៤ ភាគគឺ:

១ — ទីរាបខ្ពស់ក្នុងរដ្ឋពួកបាវីយែរ, វីរតេមប៊ែរគ៍និងបាដេន ។ ទីរាបខ្ពស់នេះចេញមកពីតំបន់ភ្នំអ័ល្ប៍ ហើយលាតចុះទាបទៅខាងជើងទន្លេដានុប ។

២ — ទីទំនាបជើងទន្លេរ៉ាំងត្រង់កណ្ដាលៗផ្ទៃផែនដីចំណែកនេះប្រកបដោយភ្នំនិងទំនាបជើងភ្នំ មានដីជីជាតិល្អ ។

៣ – ភាគកណ្ដាលរបស់ប្រទេសអល្លឺម៉ាញ ផ្ទៃផែនដីភាគនេះប្រកបដោយជួរភ្នំវែងៗដូចភ្នំហារ៍សជាដើម តាមចង្កេះភ្នំដេរដាសដោយព្រៃឈើយ៉ាងស្អុក ។

៤ – ទំនាបភាគខាងជើង ផ្ទៃផែនដីភាគនេះជាចំណែកមួយនៃទំនាបធំរបស់ទ្វីបអឺរ៉ុប មានភាណា ខេត្តតាំងអំពីហុល្លង់រហូតដល់ប្រទេសប៉ូឡូញ មានដងទន្លេវែងៗ ហើយមានទន្លេសាបធំៗជាច្រើននៅក្នុងទំនាបនេះ ផ្ទៃផែនដីទិសខាងលិចដែលជាប់ព្រំប្រទល់នឹងប្រទេសបែលហ្ស៊ិក នឹងប៉េអ៊ី-បាស់ ជាទីមានដីជាតិល្អតែនៅខាងសមុទ្រប័លទិក នឹងនៅខាងប្រទេសប៉ូឡូញជាដីល្បាយខ្សាច់ ។

៥ – ផ្ទៃដីភាគខាងជើងរបស់ប្រទេសអល្លឺម៉ាញមិនសូវមានដីជាតិទេ ពួកអ្នកស្រែតែងប្រើជីដាក់ផងជាដរាប នៅទីដីមិនមានដីជាតិដូច្នេះគេប្រើដាំស្មៅ, ស្រូវនឹងដំឡូងបារាំង ។

ទន្លេ – ទន្លេសំខាន់របស់ប្រទេសអល្លឺម៉ាញមាន ៥ អន្លើគឺ ទន្លេរ៉ាំង (១២១៦ គ.ម.) ទន្លេអែលប៍ (១១០៤ គ.ម.) អូឌែរ (៨៨០. គ.ម) វែស៊ែរ (៦០៨ គ.ម.) នឹងដានូប ជាទន្លេនៅប្រទេសអល្លឺម៉ាញ មានលក្ខណៈដូចទន្លេក្នុងប្រទេសបារាំងសែស គឺមានទឹកហូរយឺតៗ ស្រួលដល់ការធ្វើដំណើរតាមនាវា ហើយមានផ្លូវទឹកច្រើនហូរធ្លាក់ទៅក្នុងសមុទ្រទិសខាងលិចឆៀងខាងជើង ។

**ខ្យល់អាកាស** — នៅភាគខាងលិច, ខាងត្បូងនិងខាងជើងមានអាកាសមធ្យម នៅភាគខាងកើតមានអាកាសរងាខ្លាំងក្ដៅខ្លាំង មានភ្លៀងធ្លាក់តែល្មមសមគួរ នៅក្រុងបែរឡាំងមានភ្លៀងធ្លាក់ប្រមាណក្នុង ១ ឆ្នាំ ៥៨០ មិល្លីម៉ែត្រ នៅព្រៃព្រឹក្សានិងភ្នំមានភ្លៀងធ្លាក់ជាច្រើន ។

**ការដាំដំណាំ** — ប្រទេសអល្លឺម៉ាញមានការដាំដំណាំយ៉ាងសំបើម តែដំណាំដែលគេដាំជាច្រើនបំផុតនោះ គឺស្មៅសត្វ ស្រូវអូក្ស៍ និងដំឡូងបារាំង បន្ទាប់មក គឺស្រូវប្លេ បែត្តរ៉ាវសម្រាប់ធ្វើស្ករ ដំឡូងបារាំងសម្រាប់ធ្វើស្រា ហូប្លុងសម្រាប់ធ្វើប៊ីយែរ និងស្រូវផ្សេងៗទៀត មានដាំជាច្រើននៅភាគខាងជើង ។ ស្ដៃដាំច្រើននៅភាគកណ្ដាលនិងភាគខាងលិច ហូប្លុងដាំច្រើននៅក្នុងរដ្ឋបាវីយ៉ែរ ទំពាំងជូរដាំច្រើននៅត្រើយទិសខាងកើតនៃទន្លេរ៉ាំង ។

**លោហធាតុ** — ប្រទេសអល្លឺម៉ាញមានលោហធាតុជាច្រើន លោហធាតុសំខាន់បំផុតគឺធ្យូងថ្ម ដែលមាននៅទីទំនាបដងទន្លេក្នុងខេត្តវេស្តហ្វាលី និងដងទន្លេសារ៍ជិតប្រទល់ដែនបារាំងសែស ដែកមានច្រើនក្នុងខេត្តវេស្តហ្វាលី ក្នុងស៊ីលេស៊ីនិងស័ក្ស៍ ស័ង្កសី (ច្រើនបំផុតក្នុងលោក) មានច្រើននៅក្នុងស៊ីលេស៊ី ជាតំបន់ព្រៃខ្មៅនិងភ្នំហារ៍ស អំបិលមានច្រើននៅក្នុងស័ក្ស៍ ប៉ូតាស្យូមមានច្រើនបំផុតក្នុងលោក នៅតំបន់

ស្កាសប្បារក៍ នៅទិសខាងលិចទៀតខាងត្បូងស្រុកម៉ុកដឺប្បូរក៍ មាន លោហធាតុអស់នេះគឺ សំណកក់, សំណប៉ាហាំង, ទង់ដែង, ប្រាក់ ទឹង នីកែល ។

លោហធាតុសំខាន់បំផុតដែលជីកបានក្នុង ព.ស. ២៤៨៣ មាន ចំនួនដូច្នេះ គឺធ្យូងថ្ម ២៨៩ លានតោន រ៉ែដែក ៥,៧៤១,២០៥ តោន (បានសាច់ដែក ១,៨៣៤,៣៣៨ តោន) រ៉ែស័ង្កសី ២៧៣,២៧៤ តោន (បានស័ង្កសី ១៣៨,៦៥៣ តោន) រ៉ែទង់ដែង ៨៤៥,៦១៩ តោន, ប៉ូ-តាសសុទ្ធ ១,៣៥១,៤២០ តោន សំណ ១៨២,១៤០ តោន នឹងប្រេងកាត ១៧៤,៣២៨ តោន ។

សត្វចិញ្ចឹម — ក្នុង ព.ស. ២៤៧៤ មានចំនួនដូច្នេះ ជ្រូក ២៣,៧៨៣,៤០០, គោ ១៩,០៩០,៥០០, ពែះ ៧,៤៩៥,០០០ សេះ ៣,៤៧៧,៧០០ ពពែ ២,៥១៤,៤០០ ។

(នៅមានត)

## ពង្សាវតាររោម

(តទក)

ពិធីដែលគេនិយមធ្វើជានិច្ចនោះ គឺកាលបើបានជ័យជំនះហើយ ទាហានក៏ប្លន់ដណ្ដើមយកទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងស្រុកនោះ ៗ ទ្រព្យសម្បត្តិនិងពួកឈ្លើយត្រូវនាំមកកាន់ក្រុងរោមហើយដាក់លក់ រឿងនេះរដ្ឋបាលជាអ្នកចាត់ការលក់ដូរ ហើយបែងរាយចំណែកទុកជាចំនួនច្រើន សល់ពីនោះក៏ចែករំលែកទៅក្នុងពួកក្រុមទាហាន ហេតុនេះបានជាឃ្លាំងរបស់រដ្ឋបាលមិនសូវមានការខ្វះខាត ៗ ជួនកាលកដការត្រូវបានទ្រព្យសម្បត្តិជាចំនួនច្រើនៗក៏មាន ដូចកាលក្រុងរោមច្បាំងឈ្នះពួកម៉ាសេដ្វាន ទ្រព្យសម្បត្តិរបស់ឈ្លើយលក់បានចំនួនប្រហែល ៣០.០០០.០០០ត្រណោត ឯរាស្ត្រប្រជាដែលមិនបានទៅច្បាំងក៏បានធូរខ្លួនមិនបាច់បង់ពន្ធដារ ពោលគឺកាលបើរដ្ឋបាលបានទ្រព្យសម្បត្តិរបស់ឈ្លើយមកជាច្រើនក្នុងវេលាណា រាស្ត្រប្រជាទាំងពួងត្រូវលើកលែងមិនបាច់បង់ពន្ធដារឆ្នាំក្នុងវេលានោះ ៗ

ពួករោមមានពិធីប្លែកជាងជនជាតិបុរាណឯទៀតៗ ក្នុងការរក្សាអំណាចស្រុកចំណុះដែលខ្លួនវាយបាននោះឲ្យខ្ជាប់ខ្លួនជានិច្ច ពោលគឺកាលបើទៅវាយស្រុកណាបាន ក៏រៀបចំដាក់ទាហានសាងបន្ទាយ ហើយក្រុម

ពាហនក៏មានគ្រួសារនៅប្រចាំក្នុងទីនោះ បែងចែកទីដីសម្រាប់ធ្វើការកសិកាល់តែក្លាយទៅជាប្រជាជនរបស់ស្រុកនោះ តែគង់នៅជាជាតិពេហ្មាំងដដែល ៗ ក្រៅពីនេះពួកពេហ្មាំងនៅតែយកចិត្តទុកដាក់ធ្វើថ្នល់ ថ្នល់ដែលពួកពេហ្មាំងកសាងទុកនោះ នៅតែប្រើការបានរហូតមកដល់សម័យនេះ ហើយអារ្យធម៌របស់ពួកពេហ្មាំងក៏ផ្សាយចេញទៅគ្រប់ច្រកគ្រប់អន្លើនៅតាមខែត្រដែនដែលពួកពេហ្មាំងធ្លាប់ធ្វើជានាយចៅហ្វាយត្រួតត្រាមកនោះ ៗ

## អំពីជ័យជំនះនៃក្រុងរោម

យើងបានដឹងហើយថា រោម នៅត្រង់ពាក់កណ្ដាលនៃប្រទេសអ៊ីតាលី ៗ ឯប្រទេសអ៊ីតាលីនេះ ជាប្រទេសសំខាន់បំផុត ក្នុងសមុទ្រមេឌីតេរ៉ាណេ ៗ ការដែលក្រុងរោមធ្វើចម្បាំងហើយមានជ័យជំនះ ត្រាតែបានធ្វើជាម្ចាស់លោកក្នុងសម័យនោះ គឺដំបូងចាប់ធ្វើការច្បាំងក្នុងប្រទេសជិតខាងខ្លួនជាមុនសិន ហើយវាយយកអាណាខេត្តឲ្យកាន់តែរីកធំចេញតទៅទៀត សរុបរួមជ័យជំនះរបស់ក្រុងរោមមាន ៣ ភាគគឺ:

ក- ជ័យជំនះក្នុងប្រទេសអ៊ីតាលី ៗ

ខ- ជ័យជំនះនៅចំណែកទិសខាងលិច ខាងសមុទ្រមេឌីតេរ៉ាណេ

គ- ជ័យជំនះនៅចំណែកទិសខាងកើត ៗ

ក- ជ័យជំនះក្នុងប្រទេសឥតាលី. ចាប់ផ្ដើមតាំងអំពីក្រុងរោមកសាងឡើងរហូតមកដល់ពុទ្ធសករាជ ២៧៧ ។ ពង្សាវតារមានហេតុសំខាន់ ២ ប្រការកើតឡើងក្នុងស្រុក គឺការដណ្ដើមអំណាចគ្នារវាងពួកប្លេបេអ៊ីយាងនឹងពួកប៉ាទ្រីស្យាំង ។ ឯការខាងក្រៅស្រុកនោះ ពួករោ-ម៉ាំងមានជ័យជំនះប្រទេសឥតាលី តាំងអំពីជួរភ្នំអាប៉ែនណាំង (Apennins) រហូតដល់កោះស៊ីស៊ីល (Sicile) ។ ហេតុគេខសំខាន់ទាំងពីរប្រការនេះមានគួគ្នាមករហូតរវាងវេលា ៤ សតវត្សរ៍ ហេតុនេះហើយបានជាបើកឱកាសឲ្យពួកប្លេបេអ៊ីយាងមានសេចក្ដីស្មើភាគគ្នានឹងពួកប៉ាទ្រីស្យាំង ។

សង្គ្រាមដែលក្រុងរោមចាប់ផ្ដើមធ្វើឡើងក្នុងជាន់ដម្បូង ៗ នោះគ្រាន់តែជាការពោមរាយប្រទេសជិតខាង ជាកដកិច្ចរបស់ក្សត្រក្រុងរោមដែលទ្រង់ធ្វើសង្គ្រាមដើម្បីពង្រីកអាណាខេត្ត តាមពិតនោះ ក្រុងរោមជាស្រុកតូចមានរូបាង ៤ ជ្រុង មានទំហំដ៏មិនប៉ុន្មានគីឡូម៉ែត្រទេ ។ ព្រះបាទទុល្លុស,ហុស្ទីលិយុស (Tullus,Hostilius) ក្សត្រអង្គទី ៣ នៃក្រុងរោម បានរាតអាណាខេត្តចេញទៅផុតដែនឡាស្យូម (Latium) ។ ព្រះបាទអង្កុស (Ancus) ក្សត្រអង្គទី ៤ ទ្រង់ពង្រីកតទៅទៀតរហូតដល់ទន្លេទីប្រ៍(Tibre) ។ លុះដល់ក្សត្រអង្គនេះក្ស័យព្រះជន្មទៅ ក្រុងរោមក៏បានជាប្រមុខនៃស្រុកផ្សេងៗដែលបានមករួបរួមគ្នាមានចំនួនដល់៣០ ស្រុក ។

# អំពីការច្បាំងតទល់នឹងអេទ្រុស្គ

ក្នុងវេលាដែលក្រុងរ៉ូមបំបរបង់ក្សត្រចេញពីរាជសម្បត្តិនោះ ជាវេលាកើតចលាចលវឹកវរក្នុងនគរ ទើបពួកអេទ្រុស្គចូលមកវាយប្លន់ក្រុងរ៉ូម ដោយមាននាយកជាតិអេទ្រុស្គម្នាក់ឈ្មោះ ពរសេន្នា ត្រាតែពួករ៉ូម៉ាំងបរាជ័យ ហើយតាំងអំពីកាលណោះមក ក្រុងរ៉ូមក៏មិនបានធ្វើជាប្រមុខពួកឡាតាំងដូចកាលជាន់ដើម ប៉ុន្តែតមកវេលាក្រោយ ពួកក្រិកនឹកខ្លាចក្រែងពួកអេទ្រុស្គមានកំឡាំងអំណាចច្រើនហួសពេកទៅ ទើបរួមកំឡាំងគ្នាច្បាំងនឹងពួកអេទ្រុស្គ ហើយក្រុងរ៉ូមក៏របូតរួចពីកណ្ដាប់ដៃពួកអេទ្រុស្គមកបាន ។ សង្គ្រាមគ្រានោះជាសង្គ្រាមដែលក្រុងរ៉ូមចាញ់ទេ តែធម្មតាមនុស្សឆ្លាតគេតែងតែរកឧបាយបំបិទបំបាំងកេរ្តិ៍ខ្មាសរបស់ខ្លួន វិធីដែលពួករ៉ូម៉ាំងលាក់បំពួនសេចក្ដីអៀនខ្មាសក្នុងការចាញ់ចម្បាំងគ្រានេះ គឺគេតែងជានិទានទំនងរឿងព្រេងនិយាយពីសេចក្ដីក្លាហានរបស់ជាតិរ៉ូម៉ាំងជាអនេកប្រការ ហួសវិស័យនឹងជឿបាន ។

(នៅមានត)

# សេចក្តីប្លែកៗ

ព្រះអវលោកិតេស្វរៈ — អស់លោក-អ្នកមើលទស្សនាវដ្តី ហើយ ធ្លាប់បានមើលសៀវភៅមគ្គុទ្ទេសក៍នគរ  គង់បានជ្រាបរឿងរ៉ាវរបស់ព្រះពោធិសត្វអវលោកិតេស្វរៈ ឬព្រះលោកេស្វរៈ ដែលគេបានកសាងឡើងក្នុងពដអាណាចក្រខ្មែរកាលពីសម័យបុរាណ ៗ តាមដោយពិត រូបនេះជារូបទេវតាថែរក្សាប្រាសាទអង្គរ  ទើបយើងឃើញរូបនេះនៅគ្រប់ខ្លោងទ្វារ នៅបរិវេណស្ពានបុរាណខ្មែរ ដូច្នេះជនជាតិខ្មែរត្រូវតែស្គាល់ឈ្មោះព្រះពោធិសត្វនេះ ដែលបុព្វបុរសរបស់ខ្លួនធ្លាប់គោរពបូជាមក ៗ ចុះឈ្មោះនេះតើបានសេចក្តីដូចម្តេច? សព្ទនេះចែកចេញជា ៣ បទគឺ អវ ១ បទ, លោក ១ បទ, ឥស្វរៈ ១ បទ, ប្រែថា  ព្រះជាម្ចាស់តែងទ្រង់ពិនិត្យមើលសកលលោក ៗ តាមយោបល់របស់ពួកអ្នកកាន់ពុទ្ធសាសនាបែបមហាយានថា  ព្រះជាម្ចាស់នេះតែងទ្រង់ទតមើលសត្វលោកដែលរងទុក្ខវេទនានៅលើដី ដែលនាំជីវិតឲ្យច្របូកច្របល់ដោយអកុសលកម្ម  ព្រះភក្ត្រតែងងាកបែរទៅជុំវិញទិស  ដើម្បីទតមើលសព្វសារពើទាំងពួងនិងជួយសង្គ្រោះលោក  ហេតុនេះហើយ បានជាគេធ្វើព្រះភក្ត្រ ៤ សម្រាប់ទិសទាំង ៤  ហើយប្រតិស្ឋានទុកគ្រប់ប្រាសាទនិងតាមខ្លោងទ្វារប្រា-

សាទអគ្គ ៗ មួយវិញទៀត គេហៅព្រះពោធិសត្វនេះថា "លោកនាថ" ប្រែថា ជាទីពឹងនៃលោក ជាព្រះធម្មទេសរបស់ព្រះពុទ្ធ ៗ តាមជំនឿរបស់ពួកមហាយាន ព្រះដែលមាននាមថា "អមិតាភៈ" ប្រែថា ព្រះពុទ្ធដែលមានរស្មីនឹងគិតគណនាពុំបាន ហេតុនេះហើយបានជាព្រះពោធិសត្វអវលោកិតេស្វរៈ មានរូបព្រះពុទ្ធស្ថិតនៅទីផ្ចិតសក់ជានិច្ច ៗ

**អំពីខេត្តបេង្គល់នៅប្រទេសឥណ្ឌា** – ខេត្តនេះនៅក្នុងចន្លោះទន្លេធំៗ ទាំងពីរ គឺទន្លេគង្គានឹងទន្លេព្រហ្មបុត្រ ៗ នៅទិសខាងជើងខេត្តនេះ មានព្រំប្រទល់នឹងទណ្ឌសីមាប្រទេសនេប៉ាល់ ដែលជាតំបន់ជាទីកើតនៃពុទ្ធសាសនា ទិសខាងលិចមានព្រំប្រទល់នឹងខេត្តនានានៅឥណ្ឌាកណ្តាល នៅទិសខាងត្បូងទល់នឹងសមុទ្រ ដែលជាឈូងសមុទ្របេង្គល់ ទិសខាងកើតជាប់នឹងខេត្តដែនភូមា ដែលជាប្រទេសកាន់ព្រះពុទ្ធសាសនា ៗ ក្នុងខេត្តបេង្គល់សព្វថ្ងៃនេះ មានចំនួនអ្នកកាន់ពុទ្ធសាសនាតិចទេ ក្នុងចំពួកសាសនាផ្សេងៗនោះ ព្រះពុទ្ធសាសនានៅក្នុងជួរទី ៤ នៅជំណែកទិសខាងលិចនៃខេត្តនេះ បានទទួលលទ្ធិពុទ្ធសាសនាដែលជាប្រសគល់ដើមរបស់សាសនា តែពួកពុទ្ធសាសនាសព្វថ្ងៃនេះជាពួកមហាយាន ហើយមានតែពួកមនុស្សដែលមកពីនេប៉ាល់ (ស្រុកដែលព្រះពុទ្ធកើត) និងមកពីប្រទេសទីបេតជាចំនួនច្រើន ៗ

លទ្ធិសាសនាហិណ្ឌូអ៊ីស្លាំបានបំបាត់ពុទ្ធសាសនាក្នុងតំបន់នេះឯង តំបន់នេះហើយដែលគេនាំវិធិគ្រប់គ្រងវណ្ណៈចូលមកផ្សាយ ហើយថែមទាំងមហាក្សត្របានជួយទំនុកបំរុងបីបាច់គេ ក៏ការប្រកាន់វណ្ណៈនេះហើយ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធៈតាលជាដំបូង ហើយទេវរូបផ្សេងៗក្នុងសាសនាព្រាហ្មណ៍ក៏បានមកនៅជិតខាងគ្នានឹងព្រះពុទ្ធរូបនៅជាមួយគ្នាទាំងពីរសាសនា ហើយសាសនិកជន (ទាំងពីរពួក) បាននាំគ្នាទៅគោរពពិធីបូជាយញ្ញឡើងវិញ ។

ឥឡូវនេះ ពុទ្ធិកសមាគមហៅថា "មហាពោធិ" បានចាត់បញ្ជូនគណៈធម្មទូតទៅទិសខាងកើតខេត្តបេង្គ័ល (ដែលជាប់នឹងដីប្រទេសភូមា) ហើយបានតែងដឹកនាំប្រជាជនមួយចំណែកឲ្យចូលក្នុងលទ្ធិសាសនាដ៏បរិសុទ្ធ ហើយគណៈធម្មទូតនេះបានធ្វើការប្រសើរណាស់ ទើបនាំឲ្យគណៈសង្ឃហីនយានចំរើនឡើងច្រើន ។

## ក្នុងព្រះពុទ្ធសាសនាមានព្រះជាម្ចាស់សួគ៌ឬគ្មានទេ?

មានអ្នកប្រាជ្ញធំម្នាក់ជាតិបែល្ស៍ ដែលបានឧទ្ទិសជីវិតក្នុងការសិក្សាព្រះពុទ្ធសាសនាទាំងប៉ែកខាងមហាយានទាំងប៉ែកខាងហីនយាន លោកបានពិនិត្យមើលអំពីពាក្យចោទសួរខាងលើនេះ ហើយលោកបានពោលទុកថា ប្រសិនបើគេទុកពុទ្ធសាសនាតាមយោបល់ខាងបរមត្ថវិជ្ជា

វិញ លទ្ធិសាសនានេះមែនទែនទាស់ទឹងគំនិតយោបល់និយាយអំពីទេព-វិសេសជាន់ខ្ពស់ឬព្រះម្ចាស់សួគ៌តាមដែលពួកឤរុបតែងយល់មកនោះ ៗ ពួកពុទ្ធសាសនិកជនតែងជឿថា អំពើល្អអាចមានអំពើអាក្រក់មកចូលផង ហើយដណ្ដើមគ្នាឲ្យផលល្អ - អាក្រក់តែរៀងខ្លួន ពុទ្ធសាសនិកជនតែងសរសើរអំពីកិរិយាឈឺចិត្តស្ដាយក្រោយ ត្រង់ការដែលខ្លួនធ្វើខុស ហើយលើកចិត្តគំនិតឲ្យប្រព្រឹត្តទៅតាមអំណាចនៃកម្ម ដែលគេទុកជាកំឡាំងខាងសតិបញ្ញា (ចាត់ចែងកិច្ចការទាំងពួង) ៗ

កាលបើមើលគម្ពីរបាលីជាច្រើនគម្ពីរទៅ គេយល់ច្បាស់ថា ទេវតាទាំងឡាយតែងគោរពព្រះព្រហ្ម ហើយព្រះព្រហ្មនៅក្រោមព្រះពុទ្ធទេ ៗ ក្នុងគម្ពីរក្រោយ ៗ មករបស់ព្រះពុទ្ធសាសនា មានលក្ខណ៍យ៉ាងដាច់ស្រេចថាមិនមានព្រះម្ចាស់សួគ៌ ដែលទ្រង់កសាងនិងចាត់ចែងលោកនេះទេ ហើយលោកអ្នកប្រាជ្ញបានពោលអាងដល់រឿងមួយ ក្នុងគម្ពីរមួយជាភាសាសំស្ក្រឹតប៉ែកខាងមហាយាន ដែលព្រះថេរៈ ១ អង្គឈ្មោះសន្តិទេវៈបានតែងឡើងក្នុងព.ស. ១១៩១ ៗ សេចក្ដីនេះលោកបានដកស្រង់យកអំពីគម្ពីរហៅថា "ពោធិចរិយាវតារៈ" ឬដំណើរទៅកាន់ពោធិញ្ញាណ គឺសេចក្ដីត្រាស់ដឹង ៗ "ទេវតាជាវត្ថុហួសនឹងជឿតាមបាន សូម្បីតែគុណសម្បត្តិរបស់ទេវតាជាអ្នកកសាងលោកក៏ជាការជឿពុំបានដែរ . . .

ប្រសិនបើទេវតាធ្វើការដោយឥតបំណង់ទេ ក៏នៅតែប្រាកដថា ទេវតានេះជាតាសានៃលោក ប្រសិនបើទេវតានេះមានប្រាថ្នាផង ទេវតានេះក៏ទៅជាតាសានៃតណ្ហាដូច្នេះ នេះឬជាគុណសម្បត្តិរបស់ទេវតាជាអ្នកកសាងលោក" ។

## អំពីអាវុធកាំភ្លើងក្នុងសង្គ្រាមបុរាណ

### របស់ប្រទេសឥណ្ឌូស៊ិន

តាំងអំពីព.ស. ១៩៣៦ ដែលកើតសង្គ្រាមរវាងខ្មែរនឹងសៀម គេចេះប្រើអាវុធកាំភ្លើងក្នុងចម្បាំង ហើយនៅក្នុងព.ស. ១៨៩៧ ពួកកូមាមានកាំភ្លើងធំប្រើហើយ ។ គ្រឿងអាវុធកាំភ្លើងនេះពួកអាក៉ប់បាននាំចូលមកក្នុងស្រុកដោយប្រទេសមលេស៍ តាមផ្លូវស្រុកក្លិង្គ ។ នៅក្នុងស្រុកចិនគេក៏ចេះប្រើកាំភ្លើងធំនឹងអាវុធកាំភ្លើងតាំងពីព.ស. ១៩៥០ ។ ពាក្យខ្មែរថា "មើរៀន" នឹងពាក្យសៀមថា "បារៀម" នោះសំដៅយកកាំភ្លើងធំកំណើតពាក្យនេះមកពីពាក្យអាក៉ប់ ផ្សាយចូលមកតាមប្រទេសមលេស៍ ។ កំណើតដើមពាក្យមកពីពាក្យថា ម៉ារី, ម៉ារីយ៉ា (Marie, maria) ជាពាក្យអាក៉ប់ប្រើហៅកាំភ្លើងធំ ព្រោះកាំភ្លើងធំដំបូងដែលពួកអាក៉ប់ស្គាល់នោះជារបស់ដែលពួកគ្រិស្តប្រើការក្នុងទ្វីបឲរុប ឯពាក្យថា ម៉ារី ទើបក្លាយជាឈ្មោះម្ដាយរបស់ព្រះគ្រិស្ត ។

# រឿងសេដ្ឋីបីនាក់

មាននិទានមួយដំណាលថា នៅក្នុងស្រុកមួយ មានសេដ្ឋីបីនាក់ សេដ្ឋីមួយនៅទិសខាងកើត សេដ្ឋីមួយនៅកណ្ដាល សេដ្ឋីមួយទៀត នៅទិសខាងលិច ឯសេដ្ឋីនៅកណ្ដាលមានកូនក្រមុំមួយរូបឆោមល្អ ទើបសេដ្ឋីនៅទិសខាងលិចចាត់ចែងបណ្ណាការឲ្យគេទៅដណ្ដឹងកូនក្រមុំសេដ្ឋីនោះ ជូនជាថ្ងៃដែលទៅដណ្ដឹងនោះ សេដ្ឋីជាឪពុកមិននៅ តែម្ដាយៗក៏ស្រុះស្រួលឲ្យកូនទៅសេដ្ឋីនៅទិសខាងលិច ។ តមក សេដ្ឋីនៅទិសខាងកើតបានចាត់ចែងបណ្ណាការឲ្យមនុស្សទៅនិយាយដណ្ដឹងកូនក្រមុំសេដ្ឋីនោះដែរ តែគាប់ជួនថ្ងៃនោះនៅតែឪពុក ម្ដាយទៅកាន់ទីដទៃ ឪពុកក៏យល់ព្រមឲ្យកូនទៅសេដ្ឋីទិសខាងកើត ឯប្រពន្ធពុំដឹងថាប្ដីលើកកូនក្រមុំឲ្យទៅសេដ្ឋីនៅទិសខាងកើតឡើយ លុះដណ្ដឹងស្រេចហើយក៏កំណត់ថ្ងៃរៀបមង្គលការជាមួយគ្នា ហើយសេដ្ឋីទាំងពីរនាក់ ចាត់អ្នកផ្ទះទៅមហារៀបគ្រឿងបណ្ណាការក្រយាសំពះ នាំទៅជូនឪពុកក្មេកម្ដាយក្មេក ស្រាប់តែទៅជួបប្រទះគ្នានៅផ្ទះឪពុកក្មេកម្ដាយក្មេក ហើយតាំងដណ្ដើមគ្នា មួយថា ស្រីនេះជាប្រពន្ធអញ ម្ដាយលើកឲ្យអញ ។ សេដ្ឋីមួយទៀតថា ស្រីនេះប្រពន្ធអញ ឪពុកលើកឲ្យអញ ។ សេដ្ឋីទាំងពីរដណ្ដើមគ្នាជ្ជេះ ហើយ ក៏នាំគ្នាទៅប្ដឹងចៅក្រមសុំឲ្យចៅក្រមកាត់សេចក្ដីនេះតើត្រូវបាន

ទៅខាងណា ឯអស់ចៅក្រមអារកាត់សេចក្តីនោះពុំបានឡើយ ទើបសេដ្ឋីទាំងពីរនាំគ្នាឡើងទៅក្រាបបង្គំទូលសេចក្តីនោះ ដល់សម្តេចព្រះមហាក្សត្រ ទើបព្រះអង្គមានព្រះបន្ទូលថា ហៃសេដ្ឋីទាំងពីរអើយ ហេតុដំណើរអ្វីក៏ប្រស្តងនាំគ្នាមកប្តឹងប្តល់? ទើបសេដ្ឋីនៅទិសខាងកើតក្រាបបង្គំទូលថា ខ្ញុំព្រះអង្គឲ្យគេទៅដណ្តឹងកូនក្រមុំសេដ្ឋីម្នាក់ដល់ម្តាយអាពុក តែជួនជាពុំចួបនឹងម្តាយឡើយ ឃើញតែអាពុកៗក៏ព្រមឲ្យកូនមកខ្ញុំព្រះអង្គជាប់ស្រឡះហើយ ទើបខ្ញុំព្រះអង្គរៀបគ្រឿងបណ្ណាការក្រយាសំពះទៅប្រទះគ្នានៅមុខផ្ទះម្តាយអាពុកនោះ ទើបដណ្តើមគ្នាកើតជាក្តី ហើយនាំគ្នាមកក្រាបទូលឲ្យទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទនេះតែប៉ុណ្ណោះឯង ៗ ទើបព្រះអង្គបន្ទូលដណ្តឹងទៅសេដ្ឋីមួយទៀត ៗ សេដ្ឋីនៅទិសខាងលិចក៏ក្រាបទូលថា ខ្ញុំព្រះអង្គឲ្យគេទៅដណ្តឹងម្តាយអាពុក តែចួនជាពុំឃើញអាពុកឡើយ ឃើញតែម្តាយៗលើកឲ្យខ្ញុំព្រះអង្គជាស្រឡះហើយ ទើបខ្ញុំព្រះអង្គរៀបរណ្តាប់ទៅសំពះ ស្រាប់តែប្រទះគ្នានៅមុខផ្ទះម្តាយអាពុក ទើបដណ្តើមគ្នាកើតជាក្តី នាំគ្នាមកក្រាបទូលឲ្យទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទដោយដំណើរអស់តែប៉ុណ្ណោះឯង ៗ ទើបព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថាគួរឲ្យសេដ្ឋីដែលម្តាយលើកប្រគល់ឲ្យ ដ្បិតម្តាយបានបីថ្នមនឿយហត់លើសក្រៃលែងជាងអាពុក ៖ហេតុដំណើរនេះ

ហោង ទើបទ្រង់វិនិច្ឆ័យថា ត្រូវឲ្យកូនក្រមុំទៅជាប្រពន្ធសេដ្ឋីនៅទិសខាងលិច ឯសេដ្ឋីនៅទិសខាងកើតដែលអាពុកលើកឲ្យនោះ មិនត្រូវបានទេ ព្រោះកូនស្រីអាពុកមិនសូវបានថែទាំដូចជាម្ដាយ ហើយព្រះអង្គមានបន្ទូលផ្សះផ្សាឲ្យសេដ្ឋីទាំងពីរចងមេត្រីនឹងគ្នាតរៀងទៅ ឯសេដ្ឋីទាំងពីរនាក់ក្រាបបង្គំទូលលាទៅកាន់លំនៅរៀងខ្លួនហោង ។

ចប់រឿងសេដ្ឋីបីនាក់តែប៉ុណ្ណោះ ។